ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
លេខ : ០០៤/២៤ សសរ.អ.ដ.ក

# សេចក្តីសម្រេច

# ស្តីពី

# លក្ខន្តិកៈនៃមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

(ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤)

២០២៤

មាតិកា

**សេចក្ដីសម្រេច**

**ស្ដីពី**

**លក្ខន្តិកៈនៃមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**

**នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

(ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤)


| |
|---|
| **ជំពូកទី១ បទប្បញ្ញត្តិទូទៅ**<br>(ប្រការ១ដល់ប្រការ៣) |
| **ជំពូកទី២ លក្ខខណ្ឌនៃការចូលបំពេញការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**<br>(ប្រការ៤ដល់ប្រការ៧) |
| **ជំពូកទី៣ លក្ខខណ្ឌនៃការបំពេញការងារ និងអត្ថប្រយោជន៍ដែលទទួលបានពីការបំពេញការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**<br>(ប្រការ៨ដល់ប្រការ១០) |
| **ជំពូកទី៤ ពេលវេលាបំពេញការងារ ការឈប់សម្រាក និងការព្យួរកិច្ចសន្យាការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**<br>(ប្រការ១១ដល់ប្រការ១៣) |
| **ជំពូកទី៥ ការចោទប្រកាន់តាមផ្លូវតុលាការ និងទណ្ឌកម្មវិន័យចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**<br>(ប្រការ១៤ដល់ប្រការ១៧) |
| **ជំពូកទី៦ ការដកហូតនីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ**<br>(ប្រការ១៨) |
| **ជំពូកទី៧ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត**<br>(ប្រការ១៩ដល់ប្រការ២៤) |
| **ជំពូកទី៨ អវសានប្បញ្ញត្តិ**<br>(ប្រការ២៥) |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
លេខ : ០០៤/២៤ សសរ. អ.ជ.ក.

# សេចក្តីសម្រេច
# ស្តីពី
# លក្ខន្តិកៈនៃមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

## អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពី ការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- បានឃើញអនុក្រឹត្យលេខ ៣៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- បានឃើញសេចក្តីសម្រេចលេខ ០០២/២៤ សសរ. អ.ជ.ក. ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពី បែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- យោងតាមស្មារតីនៃកិច្ចប្រជុំអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នាសម័យប្រជុំថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

សេចក្តីសម្រេចនេះ កំណត់អំពីលក្ខន្តិកៈនៃមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃអាជ្ញាធរជាតិ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយ



មហាវិថីឈ្នះៗ ភូមិព្រែកតាវ័ត្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ Email: nadr@moj.gov.kh

វិវាទក្រៅប្រព័ន្ធតុលាការ (**អ.ជ.ក.**) តាមរយៈការរៀបចំនូវយន្តការនៃការគ្រប់គ្រង និងការបំពេញការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.**។

**ប្រការ២ ..**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តទាំងអស់ ដែលទទួលបាននីតិសម្បទាពី **អ.ជ.ក.**។

**ប្រការ៣ ..**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ គឺជាមន្ត្រីដែលត្រូវបានជ្រើសរើស និងទទួលបាននីតិសម្បទាពី **អ.ជ.ក.** ដើម្បីអនុវត្តមុខងារសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.**។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត គឺជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដែលត្រូវបានជ្រើសរើស និងទទួលបាននីតិសម្បទាពី **អ.ជ.ក.** ដើម្បីអនុវត្តមុខងារសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.** ដោយពុំទទួលយកប្រាក់បំណាច់។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **អ.ជ.ក.**។

## ជំពូកទី២
## លក្ខខណ្ឌនៃការចូលបំពេញការងារ
## របស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

**ប្រការ៤ ..**

ការជ្រើសរើស និងការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ព្រមទាំងការធ្វើសច្ចាប្រណិធានរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវធ្វើឡើងដោយអនុលោមតាមសេចក្តីសម្រេចស្តីពីបែបបទ នីតិវិធី និងគុណវុឌ្ឍិសម្រាប់ការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

**ប្រការ៥ ..**

មុនពេលចាប់ផ្តើមបំពេញការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវចុះកិច្ចសន្យាការងារជាមួយ **អ.ជ.ក.**។ ទម្រង់ និងខ្លឹមសារនៃកិច្ចសន្យាការងារនេះត្រូវកំណត់ដោយ **អ.ជ.ក.**។

**ប្រការ៦ ..**

ដើម្បីអាចចុះកិច្ចសន្យាការងារដូចមានកំណត់ក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ អ្នកប្រកបវិជ្ជាជីវៈសេរី ឬមន្ត្រីក្នុងមុខតំណែងនយោបាយ ដែលត្រូវបានជ្រើសរើសជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវបំពេញការងារពេញម៉ោងនៅ **អ.ជ.ក.** ដោយមិនប៉ះពាល់ដល់លក្ខន្តិកៈសម្រាប់ការគ្រប់គ្រងមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬលក្ខន្តិកៈសម្រាប់គ្រប់គ្រងនូវវិជ្ជាជីវៈសេរី ឬមិនប៉ះពាល់ដល់ច្បាប់ ឬបទប្បញ្ញត្តិជាធរមានដែលមានការពាក់ព័ន្ធដទៃទៀត។

**ប្រការ៧ .-**

ការចូលបំពេញការងារជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** មិនអាចប្រើប្រាស់ជាមូលដ្ឋានក្នុងការទាមទារបញ្ចូលជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈនៅក្នុងក្រសួង ឬស្ថាប័នណាមួយឡើយ។

## ជំពូកទី៣
## លក្ខខណ្ឌនៃការបំពេញការងារ និងអត្ថប្រយោជន៍ដែលទទួលបាន ពីការបំពេញការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

**ប្រការ៨ .-**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវទទួលដោះស្រាយសំណុំរឿងវិវាទតាមការចាត់តាំង និងក្រោមការត្រួតពិនិត្យរបស់ **អ.ជ.ក.**។

នៅពេលចុះអនុវត្តការងាររបស់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវប្រើប្រាស់ឯកសណ្ឋាន និងសញ្ញាសម្គាល់ ព្រមទាំងមានលិខិតបញ្ជាបេសកកម្មចេញដោយ **អ.ជ.ក.** និងត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងក្រមប្រតិបត្តិ ដែលកំណត់ដោយ **អ.ជ.ក.**។

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ មិនត្រូវប្រើប្រាស់នីតិសម្បទារបស់ខ្លួនជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទៅធ្វើការដោះស្រាយវិវាទនៅក្រៅក្របខ័ណ្ឌ **អ.ជ.ក.** ឡើយ។

**ប្រការ៩ .-**

នៅក្នុងក្របខ័ណ្ឌនៃការបំពេញការងាររបស់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ មានសិទ្ធិអំណាចក្នុងការបំពេញកិច្ចទាំងឡាយ ស្របតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ១០ .-**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវទទួលបានប្រាក់បំណាច់ប្រចាំខែ និងប្រាក់ឧបត្ថម្ភប្រតិបត្តិការដែលត្រូវកំណត់ដោយអនុក្រឹត្យ សម្រាប់ការបំពេញការងាររបស់ខ្លួន។ ក្រៅពីនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចទទួលបានប្រាក់លើកទឹកចិត្តតាមការកំណត់ដោយ **អ.ជ.ក.**។

## ជំពូកទី៤
## ពេលវេលាបំពេញការងារ ការឈប់សម្រាក និងការព្យួរកិច្ចសន្យាការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

**ប្រការ១១ .-**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវបំពេញការងាររយៈពេល ៨ (ប្រាំបី) ម៉ោង ក្នុងមួយថ្ងៃ និង ៥ (ប្រាំ) ថ្ងៃក្នុងមួយសប្តាហ៍ នៅអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.**។

ក្នុងករណីចាំបាច់ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចត្រូវបានចាត់ឱ្យបំពេញការងារតាមពេលវេលា និងទីកន្លែងផ្សេងតាមការកំណត់ដោយ **អ.ជ.ក.**។

**ប្រការ១២ ._**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ មានសិទ្ធិឈប់សម្រាកការងារដោយទទួលបានប្រាក់បំណាច់ដូចខាងក្រោម៖

១- ឈប់សម្រាកការងារតាមថ្ងៃឈប់សម្រាកដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត និងកម្មករប្រចាំឆ្នាំ។

២- ឈប់សម្រាកប្រចាំឆ្នាំចំនួន ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងមួយឆ្នាំ។

៣- ឈប់សម្រាករយៈពេល ៣ (បី) ខែ ក្នុងករណីសម្រាកលំហែមាតុភាព ដោយត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យ។

៤- ឈប់សម្រាកដោយមានជំងឺ ឬមានគ្រោះថ្នាក់ ដោយត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យ។

ចំពោះការឈប់សម្រាកដូចមានចែងក្នុងចំណុចទី២ នៃកថាខណ្ឌទី១ ខាងលើ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវដាក់ពាក្យសុំឈប់សម្រាកឱ្យបានយ៉ាងតិច ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃឈប់សម្រាក ហើយត្រូវមានការអនុញ្ញាតពីអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** សម្រាប់ការឈប់រយៈពេលខ្លី ចាប់ពី ១ (មួយ) ថ្ងៃ ដល់ ៥ (ប្រាំ) ថ្ងៃ និងត្រូវដាក់ពាក្យសុំឈប់សម្រាកឱ្យបានយ៉ាងតិច ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃឈប់សម្រាក ហើយត្រូវមានលិខិតអនុញ្ញាតចេញដោយប្រធាន **អ.ជ.ក.** សម្រាប់ការឈប់ចាប់ពីរយៈពេល ៦ (ប្រាំមួយ) ថ្ងៃឡើងទៅ។

ចំពោះការឈប់សម្រាកដូចមានចែងក្នុងចំណុចទី៣ នៃកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវដាក់ពាក្យសុំឈប់សម្រាកឱ្យបានយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនថ្ងៃឈប់សម្រាក ហើយត្រូវមានលិខិតអនុញ្ញាតចេញដោយប្រធាន **អ.ជ.ក.**។

ចំពោះការឈប់សម្រាកដូចមានចែងក្នុងចំណុចទី៤ នៃកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវធ្វើលិខិតយុត្តិកម្មស្នើសុំការអនុញ្ញាតពីអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ក្នុងរយៈពេលយ៉ាងយូរបំផុត ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃមានជំងឺ ឬថ្ងៃជួបគ្រោះថ្នាក់ សម្រាប់ការឈប់រយៈពេលខ្លី ចាប់ពី ១ (មួយ) ថ្ងៃ ដល់ ៥ (ប្រាំ) ថ្ងៃ និងត្រូវធ្វើលិខិតយុត្តិកម្មស្នើសុំការអនុញ្ញាតពីប្រធាន **អ.ជ.ក.** ក្នុងរយៈពេលយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃមានជំងឺ ឬជួបគ្រោះថ្នាក់ សម្រាប់ការឈប់ចាប់ពីរយៈពេល ៦ (ប្រាំមួយ) ថ្ងៃឡើងទៅ។ ក្នុងករណីជំងឺ ឬគ្រោះថ្នាក់នោះមានសភាពធ្ងន់ធ្ងរ រយៈពេលដាក់លិខិតយុត្តិកម្មនេះអាចត្រូវបានពន្យាតាមឆន្ទានុសិទ្ធិរបស់ប្រធាន **អ.ជ.ក.**។

**ប្រការ១៣ ._**

ក្នុងករណីមានមូលហេតុចាំបាច់ផ្ទាល់ខ្លួន មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចស្នើសុំមក **អ.ជ.ក.** តាមរយៈអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ដើម្បីព្យួរកិច្ចសន្យាការងារ សម្រាប់រយៈពេលមិនលើសពី ៣ (បី) ខែ ក្នុងការស្នើសុំម្តងៗ។ ការស្នើសុំព្យួរកិច្ចសន្យាការងារអាចត្រូវបានធ្វើឡើងយ៉ាងច្រើន ២ (ពីរ) ដង ដែលការស្នើសុំព្យួរទាំងពីរដងមិនត្រូវមានរយៈពេលសរុបលើសពី ៦ (ប្រាំមួយ) ខែ។ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការត្រឡប់ចូលមកបំពេញការងារវិញ មក **អ.ជ.ក.** តាមរយៈ

អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ឱ្យបានយ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ មុនពេលផុតកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ពុំមានសិទ្ធិទទួលបានប្រាក់បំណាច់ និងការលើកទឹកចិត្តណាមួយឡើយ។

ការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ជ.ក.**។

## ជំពូកទី៥
## ការចោទប្រកាន់តាមផ្លូវតុលាការ និងទណ្ឌកម្មវិន័យ ចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

### ប្រការ១៤ ..

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា ត្រូវបានផ្អាកពីការងារជាបណ្តោះអាសន្ន។ ក្នុងអំឡុងពេលផ្អាកពីការងារជាបណ្តោះអាសន្ននេះ ប្រាក់បំណាច់ និងប្រាក់លើកទឹកចិត្តរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ត្រូវបានផ្អាក។

ក្នុងករណីដែលមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ទទួលបានការលើកលែងការចោទប្រកាន់ ឬត្រូវបានសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ជាស្ថាពរ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនោះត្រូវបានទទួលឱ្យចូលធ្វើការវិញបាន ប្រសិនបើកិច្ចសន្យាការងារនៅមានសុពលភាព ឬនៅមានតម្រូវការសម្រាប់ **អ.ជ.ក.**។

ទោះបីជាមានសេចក្តីសម្រេចពីតុលាការលើកលែងចោទប្រកាន់ ឬសម្រេចឱ្យរួចផុតពីបទចោទប្រកាន់ ឬផ្តន្ទាទោសក្តី ប្រសិនបើមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទបានប្រព្រឹត្តខុសនឹងក្រមសីលធម៌ និងក្រមប្រតិបត្តិរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** សាមីខ្លួនអាចត្រូវទទួលរងនូវទណ្ឌកម្មវិន័យពី **អ.ជ.ក.**។

### ប្រការ១៥ ..

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ដែលប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌ និងក្រមប្រតិបត្តិរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ និងបញ្ញត្តិដែលមានចែងក្នុងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកថាមានកំហុសខាងវិន័យ ហើយត្រូវទទួលរងនូវទណ្ឌកម្មវិន័យ។

ទណ្ឌកម្មវិន័យដែលត្រូវអនុវត្តចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** មានដូចតទៅៈ

១- ទណ្ឌកម្មវិន័យថ្នាក់ទី១ រួមមានៈ
- ក- ការស្តីបន្ទោសដោយផ្ទាល់មាត់
- ខ- ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរដោយមានចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួនរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។

២- ទណ្ឌកម្មវិន័យថ្នាក់ទី២ រួមមានៈ
- ក- ការព្យួរនីតិសម្បទា
- ខ- ការដកហូតនីតិសម្បទា
- គ- ការចាត់ចូលក្នុងបញ្ជីហាមឃាត់មិនឱ្យធ្វើជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ឬវិជ្ជាជីវៈប្រហាក់ប្រហែលដែលត្រូវបានទទួលស្គាល់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៦ .-**

ការសម្រេចអំពីទណ្ឌកម្មវិន័យថ្នាក់ទី១ ត្រូវធ្វើឡើងដោយ **អ.ជ.ក.** តាមសំណើរបស់អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.**។

ការសម្រេចអំពីទណ្ឌកម្មវិន័យថ្នាក់ទី២ អាចធ្វើទៅបានលុះណាតែមានការស៊ើបអង្កេតជាមុនដោយក្រុមប្រឹក្សាវិន័យ ដែលត្រូវបានបង្កើតឡើងដោយសេចក្ដីសម្រេចរបស់ **អ.ជ.ក.**។ ការស៊ើបអង្កេតនេះត្រូវមានការកោះហៅមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទដែលរងការចោទប្រកាន់ពីកំហុសខាងវិន័យនោះ មកធ្វើការពន្យល់បំភ្លឺដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។ ក្រោយបញ្ចប់ការស៊ើបអង្កេត ក្រុមប្រឹក្សាវិន័យត្រូវដាក់របាយការណ៍លទ្ធផលនៃការស៊ើបអង្កេតជូន **អ.ជ.ក.** ដើម្បីពិនិត្យ និងសម្រេច។

ក្នុងករណីដែលមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទត្រូវបាន **អ.ជ.ក.** សម្រេចដាក់ទណ្ឌកម្មវិន័យថ្នាក់ទី២ ដោយការព្យួរនីតិសម្បទា ដូចមានកំណត់ក្នុងប្រការ១៥ ខាងលើ កិច្ចសន្យាការងារដែលធ្វើឡើងរវាង **អ.ជ.ក.** និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនោះ ត្រូវព្យួរដោយស្វ័យប្រវត្តិក្នុងរយៈពេលដូចគ្នាទៅនឹងរយៈពេលដែល **អ.ជ.ក.** សម្រេចព្យួរនីតិសម្បទារបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនោះផងដែរ។ ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនោះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ពុំមានសិទ្ធិទទួលបានប្រាក់បំណាច់ និងការលើកទឹកចិត្តណាមួយឡើយ។

**ប្រការ១៧ .-**

ការអនុវត្តទណ្ឌកម្មវិន័យណាមួយចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ពុំរាំងដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

## ជំពូកទី៦
## ការដកហូតនីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ

**ប្រការ១៨ .-**

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ អាចត្រូវបានដកហូតនីតិសម្បទាដោយសេចក្ដីសម្រេចរបស់ប្រធាន **អ.ជ.ក.** ក្នុងករណីណាមួយ ដូចខាងក្រោម៖

១- ការស្នើសុំរបស់សាមីខ្លួន។

២- ការបាត់បង់សមត្ថភាពបំពេញការងាររបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ។

៣- ការខកខានមិនបានចូលបំពេញការងារឡើងវិញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីផុតរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ដោយពុំមានមូលហេតុសមស្រប។

៤- ការបោះបង់ការងារ ឬអវត្តមានដោយគ្មានការអនុញ្ញាតលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

៥- ការផ្ដន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា ដោយគ្មានការព្យួរទោសទាំងស្រុង។

៦- ការទទួលទណ្ឌកម្មវិន័យថ្នាក់ទី ២ ចំណុច ខ និងចំណុច គ ដូចមានចែងក្នុងកថាខណ្ឌទី២នៃប្រការ១៥ នៃសេចក្ដីសម្រេចនេះ។

ក្នុងករណីដែលមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទណាមួយ ត្រូវបានដកហូតនីតិសម្បទា តាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើ កិច្ចសន្យាការងារដែលធ្វើឡើងរវាង **អ.ជ.ក.** ជាមួយនឹងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនោះ ត្រូវរំលាយដោយស្វ័យប្រវត្តិ។

## ជំពូកទី៧

## មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត

**ប្រការ១៩** ..

ក្នុងករណីចាំបាច់ **អ.ជ.ក.** អាចជ្រើសរើសមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ដើម្បីជួយបំពេញការងារសម្រុះសម្រួលផ្សះផ្សាវិវាទក្នុងក្របខ័ណ្ឌ **អ.ជ.ក.**។

**ប្រការ២០** ..

ការជ្រើសរើស និងការផ្តល់នីតិសម្បទាជាមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ព្រមទាំងការធ្វើសច្ចាប្រណិធានរបស់មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ត្រូវធ្វើឡើងតាមបែបបទ និងនីតិវិធីដូចគ្នានឹងការជ្រើសរើស ការផ្តល់នីតិសម្បទា និងការធ្វើសច្ចាប្រណិធានដែលអនុវត្តចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ ដែលមានចែងក្នុងប្រការ៤ នៃសេចក្តីសម្រេចនេះ។

**ប្រការ២១** ..

មុនពេលចាប់ផ្តើមបំពេញការងារក្នុងក្របខ័ណ្ឌ **អ.ជ.ក.** មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តត្រូវចុះកិច្ចសន្យាការងារជាមួយ **អ.ជ.ក.**។ ទម្រង់ និងខ្លឹមសារនៃកិច្ចសន្យាការងារនេះត្រូវកំណត់ដោយ **អ.ជ.ក.**។

**ប្រការ២២** ..

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត មិនតម្រូវឱ្យបំពេញការងារពេញម៉ោងនៅ **អ.ជ.ក.** នោះទេ ប៉ុន្តែ ត្រូវដោះស្រាយសំណុំរឿង តាមការចាត់តាំង និងក្រោមការត្រួតពិនិត្យរបស់ **អ.ជ.ក.**។ ចំនួនសំណុំរឿងអប្បបរមាប្រចាំឆ្នាំដែលមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តត្រូវធ្វើការដោះស្រាយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **អ.ជ.ក.** ដោយផ្អែកលើតម្រូវការការងារ និងបរិមាណនៃសំណុំរឿងដែល **អ.ជ.ក.** ទទួលបាន។

**ប្រការ២៣** ..

មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត ពុំមានសិទ្ធិទទួលប្រាក់បំណាច់ប្រចាំខែក្នុងក្របខ័ណ្ឌ **អ.ជ.ក.** នោះទេ ប៉ុន្តែ អាចទទួលបានប្រាក់ឧបត្ថម្ភប្រតិបត្តិការ ដែលត្រូវកំណត់ដោយអនុក្រឹត្យ។ ក្រៅពីនេះ មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្តអាចទទួលបានការលើកទឹកចិត្ត តាមការកំណត់របស់ **អ.ជ.ក.**។

**ប្រការ២៤ .-**

បញ្ញត្តិនៃប្រការ៧ ប្រការ៨ ប្រការ៩ ប្រការ១៤ ប្រការ១៥ ប្រការ១៦ ប្រការ១៧ និងប្រការ១៨ នៃសេចក្ដីសម្រេចនេះ ក៏ត្រូវអនុវត្តដូចគ្នាផងដែរ ចំពោះមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទស្ម័គ្រចិត្ត។

## ជំពូកទី៨
## អវសានបញ្ញត្តិ

**ប្រការ២៥ .-**

អនុប្រធាន និងសមាជិកនៃ **អ.ជ.ក.** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** និងមន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០២៤
**ជ. អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**និងជាប្រធាន អ.ជ.ក.**

កើត រិទ្ធ

**កន្លែងទទួល៖**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២៥
- ឯកសារ កាលប្បវត្តិ